**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តសៀមរាប**

សាលក្រមលេខៈ **០២ "ជ"/១១**

ចុះថ្ងៃទី១០ ខែ មករា ឆ្នាំ២០២៣

រឿងក្តីរដ្ឋប្បវេណីលេខ ៤៨៣ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ២០២២

ប្រភេទនៃរឿងក្តី ៖ **បណ្តឹងសុំលែងលះ**

បានបញ្ចប់ការទាញហេតុផលដោយផ្ទាត់មាត់

នៅថ្ងៃ អង្គារ ១២កើត ខែបុស្ស ឆ្នាំខាល ចត្វាស័ក ពស .២៥៦៦

ត្រូវនឹងថ្ងៃទី០៣ ខែ មករា ឆ្នាំ២០២៣

## តាងនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងខេត្តសៀមរាប

បានចេញសាលក្រមដែលមានភាគីៈ

**ដើមចោទៈ**

-ដើមចោទឈ្មោះ [redacted] លក្ខណា ភេទស្រី កើតឆ្នាំ១៩៨៣ សញ្ជាតិខ្មែរ អាសយដ្ឋាននៅ [redacted] ។

មានលោក [redacted] និងលោក [redacted] ជាមេធាវីតំណាងដោយអាណត្តិឲ្យដើមចោទ ។

**ចុងចម្លើយ ៖**

-ចុងចម្លើយឈ្មោះ [redacted] សុភា ភេទប្រុស កើតឆ្នាំ១៩៧៨ សញ្ជាតិខ្មែរ អាសយដ្ឋាននៅ [redacted] ។

## អង្គហេតុ និង ចំណុចវិវាទ

១-សាលក្រមដែលទាមទារដោយដើមចោទ

•ការទាមទាររបស់ដើមចោទៈ

ក.ឲ្យដើមចោទឈ្មោះ [redacted] លក្ខណា លែងលះពីចុងចម្លើយឈ្មោះ [redacted] សុភា ។

ខ.កំណត់ថាដើមចោទជាអ្នកមានអំណាចមេបាលើកូនឈ្មោះ [redacted] ស្រីភី ភេទស្រី អាយុ១៥ឆ្នាំ ។

គ.បែងចែកទ្រព្យរួមដូចខាងក្រោមៈ

-ដីទំហំ ៣០០ម៉ែត្រការ៉េ មានទីតាំងនៅភូមិគោកធ្លក ឃុំកណ្តែក ស្រុកប្រាសាទបាគង ខេត្តសៀមរាប ប្រគល់ឲ្យដើមចោទជាម្ចាស់កម្មសិទ្ធិ ដោយចុងចម្លើយយល់ព្រមទទួលប្រាក់កំណត់ចំនួន ១៥០០០$ ជាថ្នូរ ។

-ដីទំហំ ៣៦៤០ម² ដែលមានទីតាំងនៅភូមិខ្នារ សង្កាត់ជ្រាវ ក្រុងសៀមរាប ដើមចោទបាន

ទាមទារបន្ទាប់ធ្វើការអនុវត្តលក់ដីនេះដើម្បីសងបំណុលធនាគាររួចហើយ ប្រាក់ដែលនៅសល់ពីសំណាង គឺដើមចោទទាមទារចំនួន ៦០ % ដោយប្រគល់ចំណែកឲ្យចុងចម្លើយ៤០% ។

-ប្រគល់គ្រឿងចក្រចំនួន ៦គ្រឿង (ឡានទឹក១គ្រឿង ឡានដឹកដីចំនួន២គ្រឿង អេស្កាកាយដីចំនួន១គ្រឿង ឡានដឹកអេស្កាកាយដីចំនួន១គ្រឿង និងរ៉ូឡូកិនថ្នល់ចំនួន១គ្រឿង) ឲ្យទៅភាគីចុងចម្លើយយកទៅប្រកបមុខរបររកស៊ី។

ង.ឲ្យដើមចោទជាអ្នកទទួលបន្ទុកបង់ប្រាក់ប្រដាប់ក្តី ។

**•ចម្លើយតបរបស់ចុងចម្លើយ៖**

ខ្លួនឯកភាពតាមដើមចោទ តែលើកលែងចំពោះដីទំហំ ៣៦៤០ម² ដែលមានទីតាំងនៅភូមិខ្នារ សង្កាត់ជ្រាវ ក្រុងសៀមរាប ដែលដើមចោទបានទាមទារបន្ទាប់ធ្វើការអនុវត្តលក់ដីនេះដើម្បីសងបំណុលធនាគាររួចហើយ ប្រាក់ដែលនៅសល់ពីសំណាងគឺដើមចោទទាមទារចំនួន ៦០ % ដោយប្រគល់ចំណែកមកឲ្យខ្លួនចំនួន ៤០% គឺខ្លួនពុំយល់ព្រមតាមការទាមទាររបស់ដើមចោទទេ ដោយយល់ព្រមប្រគល់ប្រាក់ដែលនៅសល់ពីទូទាត់សងបំណុលធនាគារ គឺប្រគល់ឲ្យដើមចោទលើសពីខ្លួនចំនួន០៥% (៤៧.៥០% - ៤២.៥០%) ។

**២-ការសង្ខេបរឿង ៖**

គូភាគីបានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាជាប្តី និងប្រពន្ធ និងបានចុះសំបុត្រអាពាហ៍ពិពាហ៍លេខ ០១៩ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៥ មានសៀវភៅអាពាហ៍ពិពាហ៍លេខ ០១/២០០៥ ។ ការរស់នៅជាមួយគ្នាជាប្តីប្រពន្ធដោយបានបង្កើតកូនចំនួន២នាក់ កូនទី១ឈ្មោះ [redacted] សុភារ: ភេទប្រុស កើតថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៤ និងឈ្មោះ [redacted] ស្រីភី ភេទស្រី កើតថ្ងៃទី១៥ ខែតុលា ឆ្នាំ២០០៧ ។ ការរស់នៅជាមួយគ្នាជាប្តីប្រពន្ធមិនមានសេចក្តីសុខ ដោយមិនចុះសម្រុងនឹងគ្នា ភាគីចុងចម្លើយតែងតែបង្កជម្លោះជាមួយភាគីដើមចោទ ហើយភាគីចុងចម្លើយបានចុះចេញពីផ្ទះ ប្រកបមុខរបរផ្ទាល់ខ្លួន មិនចូលរួមផ្គត់ផ្គង់ចិញ្ចឹមកូននោះទេ។ ចំពោះទ្រព្យសម្បត្តិមានដូចជា ដី និងផ្ទះ ដែលមានក្បាលដីលេខ ១៨៧៦ ទំហំ ៣៦៤០ម² មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១៧១០០៦០២-១៨៧៦ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ មានទីតាំងនៅភូមិខ្នារ សង្កាត់ជ្រាវ ក្រុងសៀមរាប ខេត្តសៀមរាប និង ដី ទំហំ១២ម៉ែត្រ គុណនិងបណ្តោយ ២៥ម៉ែត្រ ស្មើនឹង ៣០០ម៉ែត្រក្រឡា មានលិខិតផ្ទេរសិទ្ធិកាន់កាប់ដីធ្លីលេខ ១៦១/១៥ ឃកដ ចុះថ្ងៃទី ០៧ ខែកុម្ភៈ ឆ្នាំ២០១៥ មានទីតាំងនៅភូមិគោកធ្លក ឃុំកណ្តែក ស្រុកប្រាសាទបាគង ខេត្តសៀមរាប និងគ្រឿងចក្រចំនួន៦គ្រឿង(ឡានទឹក១គ្រឿង ឡានដឹកដីចំនួន២គ្រឿង អេស្កាកាយដីចំនួន១គ្រឿង ឡានដឹកអេស្កាកាយដីចំនួន១គ្រឿង និងរ៉ូឡូកិនថ្នល់ចំនួន១គ្រឿង)។ ដើមចោទ និងចុងចម្លើយបានប្រកបមុខរបររកស៊ីជាមួយគ្នា និងបានបង្កើតកិច្ចសន្យាខ្ចីបរិភោគពីធនាគារវឌ្ឍនៈ អាស៊ី ចំកាត់ នូវបំណុលទឹកប្រាក់សរុបចំនួន ១៥០០០០$ (ដប់ប្រាំម៉ឺនដុល្លារ) អាមេរិក ក្នុងនោះភាគីដើមចោទបានយក

ប្រាក់ចំនួន ៥០០០០$ (ប្រាំម៉ឺនដុល្លារ) អាមេរិក ទៅប្រើប្រាស់ផ្ទាល់ខ្លួន និងភាគីចុងចម្លើយបានទទួលប្រាក់ចំនួន ១០០០០០$ (ដប់ម៉ឺនដុល្លារ) អាមេរិក ទៅប្រើប្រាស់ផ្ទាល់ខ្លួន ។

តាមការបំពេញនីតិវិធីត្រៀមទាញហេតុផល និង នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ កន្លងមកឃើញថា គូភាគី បានឯកភាព និងមិនឯកភាពគ្នា ។

**៣.ចំណុចគ្មានវិវាទ៖**

ដើមចោទឈ្មោះ [redacted] លក្ខណា និងចុងចម្លើយឈ្មោះ [redacted] សុភា បានព្រមព្រៀងគ្នាដូចខាងក្រោម៖

-ការលែងលះគ្នា ។

-អំណាចមេបាលើកូន ។

-ការមិនទាមទារអាហារកិច្ចចិញ្ចឹមកូន របស់ដើមចោទ ។

-ទ្រព្យសម្បត្តិរួមដែលត្រូវបែងចែកមាន៖

.ដីទំហំ ៣០០ម៉ែត្រការ៉េ មានទីតាំងនៅភូមិគោកថ្លុក ឃុំកណ្ដែក ស្រុកប្រាសាទបាគង ខេត្តសៀមរាប ប្រគល់ឲ្យដើមចោទជាម្ចាស់កម្មសិទ្ធិ ដោយចុងចម្លើយយល់ព្រមទទួលប្រាក់កំណត់ចំនួន ១៥០០០$ ជាថ្នូរ ។

.ប្រគល់គ្រឿងចក្រចំនួន ៦គ្រឿង (ឡានទឹក១គ្រឿង ឡានដឹកដីចំនួន២គ្រឿង អេស្កាកាយដីចំនួន១គ្រឿង ឡានដឹកអេស្កាកាយដីចំនួន១គ្រឿង និងរ៉ូឡូកិនថ្នល់ចំនួន១គ្រឿង) ឲ្យទៅភាគីចុងចម្លើយយកទៅប្រកបមុខរបររកស៊ី។

**៤.ចំណុចមានវិវាទ៖**

ដើមចោទឈ្មោះ [redacted] លក្ខណា និងចុងចម្លើយឈ្មោះ [redacted] សុភា មិនឯកភាពគ្នាលើអចលនវត្ថុចំនួន០១កន្លែងដូចខាងក្រោម៖

-ដីទំហំ ៣៦៨០ម៉ែ ដែលមានទីតាំងនៅភូមិខ្វារ សង្កាត់ជ្រាវ ក្រុងសៀមរាប ដើមចោទបានទាមទារបន្ទាប់ធ្វើការអនុវត្តលក់ដីនេះដើម្បីសងបំណុលធនាគាររួចហើយ ប្រាក់ដែលនៅសល់ពីសំណងគឺដើមចោទទាមទារចំនួន ៦០ % ដោយប្រគល់ចំណែកឲ្យទៅចុងចម្លើយ៤០% ចំពោះចុងចម្លើយពុំយល់ព្រមតាមការទាមទាររបស់ដើមចោទទេអះអាងថា ប្រាក់ដែលនៅសល់ពីទូទាត់សងបំណុលធនាគារ គឺប្រគល់ឲ្យដើមចោទលើសពីខ្លួនចំនួន០៥% (៤៧.៥០% -៤២.៥០%) តែប៉ុណ្ណោះ ។

## សំអាងហេតុ

តាមលទ្ធផលនៃការសាកសួរសាមីភាគី និងពិនិត្យភស្តុតាង នៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ឃើញថា ៖

គូភាគីបានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាជាប្ដី និងប្រពន្ធ និងបានចុះសំបុត្រអាពាហ៍ពិពាហ៍ លេខ ០១៩ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៥ មានសៀវភៅអាពាហ៍ពិពាហ៍លេខ ០១/២០០៥ ។ ការរស់នៅជាមួយគ្នាជាប្ដីប្រពន្ធដោយបានបង្កើតកូនចំនួន២នាក់ កូនទី១ឈ្មោះ [redacted] សុភារៈ ភេទប្រុស កើតថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ២០០៤ និងឈ្មោះ [redacted] ស្រីភី ភេទស្រី កើតថ្ងៃទី១៥ ខែតុលា ឆ្នាំ២០០៧ ។ ចំពោះទ្រព្យ



Scanned with CamScanner

សម្បត្តិមាន ដី និងផ្ទះ ដែលមានក្បាលដីលេខ ១៨៧៦ ទំហំ ៣៦៨០ម២ មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១៧១០០៦០២-១៨៧៦ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ មានទីតាំងនៅភូមិខ្នារ សង្កាត់ជ្រាវ ក្រុងសៀមរាប ខេត្តសៀមរាប និង ដី ទំហំ១២ម៉ែត្រ គុណនិងបណ្តោយ ២៥ម៉ែត្រ ស្មើនឹង ៣០០ ម៉ែត្រក្រឡា មានលិខិតផ្ទេរសិទ្ធិកាន់កាប់ដីធ្លីលេខ ១៦១/១៥ ឃកជ ចុះថ្ងៃទី ០៧ ខែកុម្ភៈ ឆ្នាំ២០១៥ មានទីតាំងនៅភូមិគោកធ្លក ឃុំកណ្តែក ស្រុកប្រាសាទបាគង ខេត្តសៀមរាប និងគ្រឿងចក្រចំនួន៦គ្រឿង (ឡានទឹក១គ្រឿង ឡានដឹកដីចំនួន២គ្រឿង អេស្កាកាយដីចំនួន១គ្រឿង ឡានដឹកអេស្កាកាយដីចំនួន១គ្រឿង និងរ៉ូឡូកិនថ្នល់ចំនួន១គ្រឿង) ។ ហើយចាប់ពីរៀបអាពាហ៍ពិពាហ៍ គូភាគីមានបំណុលមួយចំនួន ។ បន្ទាប់ពីគូភាគីបានរស់នៅជាមួយគ្នាមួយរយៈ គូភាគីរស់នៅមិនចុះសម្រុងនឹងគ្នា តែងតែឈ្លោះប្រកែកគ្នា ដែលធ្វើឲ្យប្តីអស់មនោសញ្ចេតនាជាប្តីប្រពន្ធ មិនអាចរស់នៅជាមួយគ្នាជាប្តីប្រពន្ធតទៅទៀតបានឡើយ ។

-ដើមចោទឈ្មោះ [redacted] លក្ខណា បានធ្វើសេចក្តីថ្លែងការណ៍បញ្ជាក់នៅគ្រប់នីតិវិធីថា៖ ខ្លួន សុំលែងលះពីចុងចម្លើយឈ្មោះ [redacted] សុភា ដោយការរស់នៅមិនចុះសម្រុងនឹងគ្នា មិនមានភាពជឿជាក់ទុកចិត្តគ្នា ដែលការទាមទារ ដូចមានក្នុងកម្មវត្ថុនៃពាក្យបណ្តឹងចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២២ ហើយឆ្លងតាមការ សម្របសម្រួល គ្រប់នីតិវិធីរបស់តុលាការ ខ្លួនបានឯកភាព និងទាមទារ ដូចបានបញ្ជាក់នៅក្នុងកំណត់ហេតុត្រៀម កាលពីថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២២ ។

-ចុងចម្លើយឈ្មោះ [redacted] សុភា បានធ្វើសេចក្តីថ្លែងការណ៍បញ្ជាក់នៅគ្រប់នីតិវិធីថា៖ ខ្ញុំបាទទទួលស្គាល់ការព្រមព្រៀងដូចក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ចុះថ្ងៃទី២២ ខែ ធ្នូ ឆ្នាំ២០២២ និងខ្លួនមានលទ្ធភាពបង់អាហារកិច្ចចិញ្ចឹមកូនក្នុងមួយខែៗចំនួន១០០$។ ចំណែកដីទំហំ ៣៦៨០ម២ ដែលមានទីតាំងនៅភូមិខ្នារ សង្កាត់ជ្រាវ ក្រុងសៀមរាប ដែលដើមចោទបានទាមទារបន្ទាប់ធ្វើការអនុវត្តលក់ដីនេះដើម្បីសងបំណុលធនាគាររួចហើយ ប្រាក់ដែលនៅសល់ពីសំណងគឺដើមចោទទាមទារចំនួន ៦០% ដោយប្រគល់ចំណែកឲ្យខ្លួនតែ ៤០% គឺខ្លួនពុំយល់ព្រមតាមការទាមទាររបស់ដើមចោទទេគឺខ្លួនសុំប្រគល់ ប្រាក់ដែលនៅសល់ពីទូទាត់សងបំណុលធនាគារ គឺប្រគល់ឲ្យដើមចោទលើសពីខ្លួនចំនួន០៥% (៤៧.៥០% - ៤២.៥០%) តែប៉ុណ្ណោះ ។

-ចំពោះអ្នកតំណាងដោយអាណត្តិខាងភាគីដើមចោទ បានថ្លែងការណ៍ថា គូរភាគីបានព្រមព្រៀងគ្នា ស្ទើគ្រប់ចំណុចទៅហើយលើកលែងតែចំណុច ដីទំហំ ៣៦៨០ម២ ដែលមានទីតាំងនៅភូមិខ្នារ សង្កាត់ជ្រាវ ក្រុងសៀមរាប ដើមចោទបានទាមទារបន្ទាប់ធ្វើការអនុវត្តលក់ដីនេះដើម្បីសងបំណុលធនាគាររួចហើយ ប្រាក់ដែលនៅសល់ពីសំណងគឺដើមចោទទាមទារចំនួន ៦០ % ដោយប្រគល់ចំណែកឲ្យចុងចម្លើយ ៤០% តែភាគីចុងចម្លើយពុំឯកភាពគ្នាជាមួយកូនក្តីខ្លួន។ ខ្លួនសុំសំណូមពរដល់តុលាការគប្បីសម្រេចតាមការទាមទាររបស់កូនក្តីខ្លួន ដោយមូលហេតុថា ដី ដែលជាចំណុចវិវាទនេះ ដើមឡើយគឺជាដីដែលជាអំណោយរបស់មតិកជន កូនក្តីខ្លួនតែប៉ុណ្ណោះ ហើយម្យ៉ាងទៀតកូនក្តីខ្លួនជាស្ត្រីទន់ខ្សោយបន្ទាប់ ពីលែងលះ ត្រូវទទួលបន្ទុកមើលថែកូនតែម្នាក់ឯង ។



Scanned with CamScanner

-យល់ឃើញថា ឆ្លងតាមការធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ការធ្វើសេចក្តីថ្លែងការណ៍របស់ភាគីដើមចោទ និងចុងចម្លើយ អាចបញ្ជាក់បានថា គូភាគីការរស់នៅមិនអាចចុះសម្រុងនឹងគ្នា ជាហេតុធ្វើឲ្យអស់មនោសញ្ចេតនា មិនអាចរស់នៅជាមួយគ្នាជាប្តីប្រពន្ធ តទៅទៀតបានទេ ដែលជាបញ្ហាប្រឈមមុខរបស់ភាគីប្តីប្រពន្ធ បានធ្វើឲ្យចំណងអាពាហ៍ពិពាហ៍ត្រូវបានបែកបាក់ដោយឆ្លងតាមការសម្របសម្រួល និងការផ្សះផ្សាក៏គ្មាន លទ្ធផលនឹងសង្ឃឹមថា នឹងអាចធ្វើបដិទានឡើងវិញបានឡើយ ហើយចុងចម្លើយក៏បានយល់ព្រមលែងលះពីដើមចោទផងដែរ គឺជាលក្ខខណ្ឌចាំបាច់ដែលច្បាប់អនុញ្ញាតឲ្យ សហព័ទ្ធធ្វើការលែងលះគ្នាបាន។ ដូច្នេះតុលាការគប្បីពិចារណាលើការសុំលែងលះរបស់ភាគីដើមចោទ និងចុងចម្លើយតាមមាត្រា ៩៧៨ នៃក្រមរដ្ឋប្បវេណី ។

-យល់ឃើញថា គូភាគីបានព្រមព្រៀងប្រគល់សិទ្ធិអំណាចមេបាលើកូនឈ្មោះ [redacted] ស្រីភី ភេទស្រី កើតថ្ងៃទី១៥ ខែតុលា ឆ្នាំ២០០៧ ឲ្យទៅដើមចោទឈ្មោះ [redacted] លក្ខណា ចំពោះចុងចម្លើយបុគ្គលដែលមិនមានសិទ្ធិគ្រប់គ្រងលើកូនមានសិទ្ធិទៅសួរសុខទុក្ខកូន ហើយភាគីដែលទទួលសិទ្ធិគ្រប់គ្រងលើកូនត្រូវបង្កលក្ខណៈងាយស្រួលដល់ភាគីម្ខាងទៀត តាមមាត្រា៧៣ និងមាត្រា៧៥ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍និងគ្រួសារ និងមាត្រា១០៤០ នៃក្រមរដ្ឋប្បវេណី ។

-ចំពោះអាហារកិច្ចចិញ្ចឹមកូន ដើមចោទបានបោះបង់ការទាមទារ ដូច្នេះតុលាការពុំលើកយកមកពិចារណាក្នុងការសម្រេចសេចក្តីឡើយ។

-គូរភាគីបានឯកភាពគ្នា លើទ្រព្យរួម ដោយ៖

.ដីទំហំ ៣០០ម៉ែត្រការ៉េ មានទីតាំងនៅភូមិគោកធ្លក ឃុំកណ្តែក ស្រុកប្រាសាទបាគង ខេត្តសៀមរាប ប្រគល់ឲ្យដើមចោទជាម្ចាស់កម្មសិទ្ធិ ដោយចុងចម្លើយយល់ព្រមទទួលប្រាក់កំណត់ចំនួន ១៥០០០$ ជាថ្នូរ ។

.ប្រគល់គ្រឿងចក្រចំនួន ៦គ្រឿង (ឡានទឹក១គ្រឿង ឡានដឹកដីចំនួន២គ្រឿង អេស្កាកាយដីចំនួន១គ្រឿង ឡានដឹកអេស្កាកាយដីចំនួន១គ្រឿង និងរ៉ូឡូកិនថ្នល់ចំនួន១គ្រឿង) ឲ្យទៅភាគីចុងចម្លើយយកទៅប្រកបមុខរបររកស៊ី។

ដូច្នេះគប្បីតុលាការគប្បីធ្វើការវិនិច្ឆ័យសម្រេចសេចក្តី តាមការឯកភាពគ្នា និងជាឆន្ទៈ របស់គូរភាគីដែលបានព្រមព្រៀងនៅក្នុងការសម្របសម្រួល នីតិវិធីត្រៀម និងទាញហេតុផលដោយផ្ទាល់មាត់ ។

-សេចក្តីយល់ឃើញ ចំពោះការទាមទារ លើចំណុចវិវាទអំពីប្រាក់ដែលនៅសល់ពីការទូទាត់សំណងបំណុលរួមរបស់ធនាគារ វឌ្ឍនៈ អាស៊ីចំកាត់ លើការអនុវត្តលក់អចលនវត្ថុ ដីទំហំ ៣៦៤០ម$^2$ ដែលមានទីតាំងនៅភូមិខ្វារ សង្កាត់ជ្រាវ ក្រុងសៀមរាប ដើមចោទបានទាមទារបន្ទាប់ធ្វើការអនុវត្តលក់ដីនេះដើម្បីសងបំណុលធនាគាររួចហើយ ប្រាក់ដែលនៅសល់ពីសំណងគឺដើមចោទទាមទារប្រគល់មកឲ្យខ្លួនកំណត់ចំនួន៦០% ដោយប្រគល់ចំណែកឲ្យទៅចុងចម្លើយកំណត់ចំនួន៤០% ដោយចុងចម្លើយពុំយល់ព្រមតាមការទាមទាររបស់ដើមចោទទេ ដោយអះអាងថាប្រាក់ដែលនៅសល់ពីទូទាត់សងបំណុ



Scanned with CamScanner

លរួមធនាគារ គឺខ្លួនយល់ព្រមប្រគល់ឲ្យទៅដើមចោទលើសពីខ្លួនចំនួន០៥% (ដើមចោទទទួលបាន ៥៧.៥០% - ចុងចម្លើយទទួលបាន៤២.៥០%) តែប៉ុណ្ណោះ តុលាការយល់ឃើញថា ដោយពិចារណាលើស្ថានភាពផ្សេងៗដូចជាទំហំនៃការបរិច្ចាគ របស់ភាគីដើមចោទ ចំពោះលទ្ធកម្មនៃទ្រព្យសម្បត្តិ (អំណោយមត៌កជននៃដើមចោទ) ការថែរក្សា ឬការបង្កើនទ្រព្យអំឡុងពេលអាពាហ៍ពិពាហ៍ កំរិតជីវភាពរស់នៅក្នុងពេលមានចំណងអាពាហ៍ពិពាហ៍ អាយុស្ថានភាពផ្លូវចិត្ត និងផ្លូវកាយវិជ្ជាជីវៈ ប្រាក់ចំណូល និងផលប្រយោជន៍ដល់កូនៗ(កូនទាំងពីររបស់គូរភាគី ត្រូវបានរស់នៅជាមួយដើមចោទ ដែលមានភារៈកិច្ចទំនប់បម្រុងអាហាររូបបម និងការចំណាយប្រចាំថ្ងៃ) ជាអាទិ៍ ដែលនៅក្នុងបន្ទុកអំណាចមេបារបស់ភាគីដើមចោទជាម្តាយបន្ទាប់ពីលែងលះជាមួយចុងចម្លើយ ដូច្នេះគប្បីតុលាការសម្រេចសេចក្តី ដោយបង្គាប់ឲ្យភាគីដើមចោទទទួលបានប្រាក់ដែលនៅសល់ពីទូទាត់សងបំណុលរួមធនាគារលើសកំណត់ចំនួន១០%ពីចុងចម្លើយ គឺភាគីដើមចោទទួលបាន ចំនួន៥៥% និងចុងចម្លើយ ទទួលបានចំនួន៤៥% ។

-ចំពោះប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ដើមចោទ តាមការទាមទារសាមីខ្លួន ។

## សេចក្តីសម្រេចបញ្ចប់៖

I.បង្គាប់ឲ្យឈ្មោះ [redacted] លក្ខណា ភេទស្រី កើតឆ្នាំ១៩៨៣ និងចុងចម្លើយឈ្មោះ [redacted] សុភា ភេទប្រុស កើតឆ្នាំ១៩៧៨ បញ្ឈប់ការរួមរស់បែបនីតិសង្វាសពីគ្នា ចាប់ពីពេលប្រកាសសាលក្រមនេះតទៅ ។

II.ឲ្យដើមចោទឈ្មោះ [redacted] លក្ខណា ស្ថិតនៅក្នុងភាពម៉េម៉ាយរយៈពេល១២០ថ្ងៃ ចាប់ពីថ្ងៃបានទទួលដំណឹងអំពីសាលក្រមនេះ ។

III.ប្រគល់សិទ្ធិអំណាចមេបាគ្រប់គ្រងកូនឲ្យទៅដើមចោទឈ្មោះ [redacted]លក្ខណា លើកូនឈ្មោះ [redacted] ស្រីភី ភេទស្រី កើតថ្ងៃទី១៥ ខែតុលា ឆ្នាំ២០០៧ ។

IV.ទ្រព្យសម្បត្តិរួម ត្រូវបែងចែករួមមាន៖

-ប្រគល់គ្រឿងចក្រចំនួន ០៦គ្រឿង (ឡានទឹកចំនួន០១គ្រឿង, ឡានដឹកដីចំនួន០២គ្រឿង, អេស្កាកាយដីចំនួន០១គ្រឿង ,ឡានដឹកអេស្កាកាយដីចំនួន០១គ្រឿង និងរ៉ូឡូកិនថ្មល់ចំនួន០១គ្រឿង) ឲ្យទៅភាគីចុងចម្លើយឈ្មោះ [redacted] សុភា ជាម្ចាស់កម្មសិទ្ធ ។

-ប្រគល់ដីទំហំ ៣០០ម៉ែត្រការ៉េ មានទីតាំងនៅភូមិគោកធ្លក ឃុំកណ្តែក ស្រុកប្រាសាទបាគង ខេត្តសៀមរាប ឲ្យដើមចោទឈ្មោះ [redacted] លក្ខណា ជាម្ចាស់កម្មសិទ្ធិ និងបង្គាប់ឲ្យឈ្មោះ [redacted] លក្ខណា ប្រគល់ប្រាក់កំណត់ចំនួន ១៥០០០$(មួយម៉ឺនប្រាំពាន់ដុល្លាអាមេរិក) ឲ្យទៅចុងចម្លើយឈ្មោះ [redacted] សុភា ។

-បង្គាប់ឲ្យភាគីដើមចោទឈ្មោះ [redacted] លក្ខណា មានសិទ្ធិទទួលបានប្រាក់កំណត់ចំនួន៥៥% និងចុងម្លើយឈ្មោះ [redacted] សុភា មានសិទ្ធិទទួលបានប្រាក់កំណត់ចំនួន៤៥% នៃប្រាក់ដែលនៅសល់ពីការអនុវត្តលក់អចលនវត្ថុដែលមានក្បាលដីលេខ:១៨៧៨ មានវិញ្ញាបនបត្រលេខ:១៧១០០៦០២-១៨៧៨ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ មានដីទំហំ ៣៦៨០ម² ដែលមានទីតាំងនៅភូមិខ្នារ សង្កាត់ជ្រាវ ក្រុងសៀមរាប ដើម្បីសងបំណុលរួមធានាគា វឌ្ឍនៈចំកាត់ ។



Scanned with CamScanner

V.បង្គាប់ឲ្យភាគីឈ្មោះ [redacted] លក្ខណា ត្រូវបង្កលក្ខណៈងាយស្រួលដល់ភាគីចុងចម្លើយឈ្មោះ [redacted] សុភា ក្នុងការសួរសុខទុក្ខជួបប្រាស្រ័យជាមួយកូន តាមមាត្រា៧៣ និងមាត្រា៧៥ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍និងគ្រួសារ និងមាត្រា១០៨០ នៃក្រមរដ្ឋប្បវេណី ។

VI.ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ដើមចោទ ។

សាលក្រមនេះទាញហេតុផលដោយផ្ទាល់មាត់ នៅថ្ងៃទី០៣ ខែ មករា ឆ្នាំ២០២៣ ចំពោះមុខដើមចោទ និងចុងចម្លើយ និង ប្រកាសជាសាធារណៈ នៅថ្ងៃអង្គារ ៤រោច ខែបុស្ស ឆ្នាំខាល ចត្វាស័ក ពស. ២៥៦៦ ត្រូវនឹង ថ្ងៃទី១០ ខែ មករា ឆ្នាំ២០២៣ ។

**ចៅក្រម**

ហត្ថលេខា និងត្រា: [redacted]

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃអង្គារ ៤រោច ខែបុស្ស ឆ្នាំខាល ចត្វាស័ក ពស.២៥៦៦

សៀមរាប, ថ្ងៃទី១០ ខែមករា ឆ្នាំ២០២៣

**ក្រឡាបញ្ជី**

[redacted]

បានឃើញ

ចៅក្រម

[redacted]